# Respectful

lululemon | Vendor Code of Ethics

20
21

Founded in 1998, lululemon's purpose is to elevate the world by realizing the full potential within every one of us. This includes the workers who make our products. The Vendor Code of Ethics outlines our unwavering commitment to contributing to healthy communities by fostering respectful and inclusive workplaces.

This Code is based on international standards, such as the International Labour Organization's Declaration on Fundamental Principles and Rights at Work, the Universal Declaration of Human Rights, the United Nations Guiding Principles, the OECD Due Diligence Guidance for Responsible Supply Chain in the Garment and Footwear sectors  and those of the Fair Labor Association, to which we are affiliated as a Participating Company. A commitment to these internationally recognized principles is the starting point.

These are our minimum standards that we expect all of our Vendors to comply with, and we will work with our Vendor partners to ensure they are upheld. Requirements in this Code apply to owned facilities as well as subcontractors, and upstream suppliers. Where differences or conflicts in standards arise between this Code and national or local regulations, the strictest standard applies.

This Code is complemented by compliance benchmarks. If we find that a Vendor is not in compliance with this Code and benchmarks, we will require immediate attention to corrective action. Compliance with the Vendor Code of Ethics is a condition to start and maintain a business relationship with lululemon.

# ស្មោះត្រង់ ចេះគោរព មានសុវត្ថិភាព សុខភាពល្អ មានការរួមបញ្ចូល បើកចំហ មានតម្លាភាព

## កម្មករ និងសហគមន៍ដែលមានសុវត្ថិភាព និងមានសុខមាលភាព

### សុខភាព និងសុវត្ថិភាព

អ្នកលក់ត្រូវផ្តល់ជូននូវបរិយាកាសកន្លែងធ្វើការ និងកន្លែងស្នាក់នៅប្រកបដោយសុវត្ថិភាព និងនាំមកនូវសុខភាពល្អ ដើម្បីបង្ការគ្រោះថ្នាក់ និងអន្តរាយដល់សុខភាពដែលកើតឡើងដោយសារពាក់ព័ន្ធទៅនឹង ឬកើតឡើងនៅក្នុងអំឡុងពេលធ្វើការ ឬបណ្តាលមកពីប្រតិបត្តិការនៅក្នុងទីតាំងរបស់អ្នកលក់។ កម្មករត្រូវទទួលបានការបណ្តុះបណ្តាលផ្នែកសុខភាពនិងសុវត្ថិភាពគ្រប់គ្រាន់ មានបន្ទប់ទឹកស្អាត និងទឹកស្អាតអាចពិសារគ្រប់គ្រាន់ ព្រមទាំងមានកន្លែងស្នាក់នៅស្អាត និងមានសុវត្ថិភាពដែលឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋានរបស់ពួកគេ។

### ការការពារបរិស្ថាន

អ្នកលក់ត្រូវកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលកន្លែងធ្វើការរបស់ពួកគេមានទៅលើបរិស្ថាននិងសហគមន៍ជុំវិញ និង ត្រូវមានគោលនយោបាយនិងនិតិវិធី ជាស្រេចក្នុងការគ្រប់គ្រងសារធាតុគីមីដែលបានប្រើ និងទឹកសំណល់ដែលបានបង្កើតឡើងនៅក្នុងទីតាំងរបស់ពួកគេដូចមានចែងក្នុងសៀវភៅណែនាំស្តីពីបរិស្ថានអ្នកលក់របស់ លូលូឡិមិន Lululemon ។

## ការប្រាស្រ័យទាក់ទងដោយភាពស្មោះត្រង់

### ត្រូវតែមានភាពបើកចំហ តម្លាភាព និងការសហការ

អ្នកលក់ រួមទាំង លូលូឡិមិន Lululemon ត្រូវសហការ និងចូលរួមជាប្រចាំ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានពីប្រតិបត្តិការ និងដោះស្រាយចំពោះការរកឃើញនានាដែលអាចប៉ះពាល់ដល់ការរស់នៅ របស់កម្មករ ប៉ះពាល់ដល់បរិស្ថាន ឬប៉ះពាល់ដល់សហគមន៍ជុំវិញ។ អ្នកលក់មិនត្រូវប្រើអ្នកម៉ៅការបន្ត ឬអ្នកយកការងារទៅធ្វើនៅផ្ទះដោយគ្មានការអនុញ្ញាតឡើយ ហើយអ្នកលក់ត្រូវតែផ្តល់សិទ្ធិដល់លូលូឡិមិន Lululemon ឬអ្នកតំណាងជាភាគីទីបី ដោយសហការបានពេញលេញក្នុងករណីមានសវនកម្ម ឬមានការស៊ើបអង្កេតនានា។

### ការប្រាស្រ័យទាក់ទងដោយសុច្ចរិត

អ្នកលក់ត្រូវជៀសវាងអំពើពុករលួយគ្រប់ទម្រង់ទាំងអស់ដែលរួមមានដូចជា ការជំរិតទារប្រាក់សំណូក ឬប្រើប្រាស់អំណាចផ្សេងៗដើម្បីទទួលបានផលប្រយោជន៍។

### ប្រសិទ្ធភាពនៃយន្តការបណ្តឹង

អ្នកលក់ត្រូវអនុវត្តនីតិវិធីដែលអនុញ្ញាតឱ្យនិយោជិតលើកឡើង និងដោះស្រាយបណ្តឹងត៏វ៉ានៅកន្លែងធ្វើការដោយសម្ងាត់ ជាអនាមិក និង/ឬដោយផ្ទាល់ដោយគ្មានការភ័យខ្លាចចំពោះការតបតឬការសងសឹក។ ត្រូវតែមានការផ្សព្វផ្សាយអំពីនីតិវិធីទៅដល់បុគ្គលិកទាំងអស់។ អ្នកលក់ត្រូវតែឆ្លើយតបភ្លាមៗចំពោះកង្វល់របស់និយោជិត។

### កម្មករទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ

អ្នកលក់ត្រូវបិទប្រកាសអំពីក្រមសីលធម៌នេះជាភាសាដែលនិយោជិតនិយាយនៅគ្រប់ផ្នែកសំខាន់ៗនៃកន្លែងធ្វើការ និងអគារស្នាក់នៅទាំងអស់ ហើយនិយោជិតត្រូវទទួលបានការបណ្តុះបណ្តាលស្តីពីខ្លឹមសាររបស់វា។

## កន្លែងធ្វើការដែលមានការគោរពនិងតម្លាភាព

### មិនត្រូវប្រើពលកម្មកុមារឡើយ

អ្នកលក់មិនត្រូវជួលកម្មករដែលមានអាយុតិចឡើយ យ៉ាងហោចណាស់ត្រូវមានអាយុ ១៥ ឆ្នាំឡើង ដែលជាអាយុបានបញ្ចប់កាតព្វកិច្ចសិក្សា ឬដល់អាយុដែលអាចធ្វើការបានដោយស្របច្បាប់ក្នុងស្រុក ពោលគឺអាយុណាមួយខ្ពស់ជាង។ កម្មករដែលអាយុក្រោម ១៨ ឆ្នាំ ត្រូវទទួលបានការការពារពីការធ្វើការថែមម៉ោង ការងារវេនយប់ ការងារដែលមានហានិភ័យគ្រោះថ្នាក់ ហើយភារកិច្ចរបស់ពួកគេត្រូវគោរពព្រំដែនដែលកំណត់ដោយតម្រូវការច្បាប់ និងការអនុវត្តល្អប្រសើ។

### ការបៀតបៀន ការរំលោភបំពាន និងសកម្មភាពវិន័យ

អ្នកលក់ត្រូវប្រព្រឹត្តិដាក់បុគ្គលិកគ្រប់រូបដោយការគោរព និងសេចក្តីថ្លៃថ្នូរ។ មិនត្រូវមានការលើកលែង ឬការអត់ឱនចំពោះការយាយីបៀតបៀន ដោយការប្រើពាក្យសម្តី ការយាយីផ្លូវចិត្ត ផ្លូវកាយ ឬផ្លូវភេទ ការរំលោភបំពាន ការគំរាមកំហែង ឬ សម្លុតនៅក្នុងកន្លែងធ្វើការឡើយ។

### សំណង និងអត្ថប្រយោជន៏

អ្នកលក់ត្រូវទទួលស្គាល់ថាកម្មករគ្រប់រូបមានសិទ្ធិទទួលបានប្រាក់ឈ្នួលសម្រាប់មួយសប្តាហ៍ធ្វើការទៀងទាត់ដែលគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការមូលដ្ឋានរបស់កម្មករនិយោជិត និងផ្តល់ប្រាក់ចំណូលមួយចំនួនតាមឆន្ទានុសិទ្ធិ។ កម្មករត្រូវទទួលបានប្រាក់ឈ្នួលយ៉ាងហោចណាស់ប្រាក់ឈ្នួលអប្បបរមា ឬប្រាក់ឈ្នួលទូទៅសមរម្យពោលគឺណាមួយដែលខ្ពស់ជាង និងត្រូវទូទាត់តាមអត្រាបុព្វលាភសម្រាប់ការងារថែមម៉ោង។ អ្នកលក់ត្រូវតែគោរពតាមតម្រូវការច្បាប់ទាំងអស់លើប្រាក់ឈ្នួល ហើយផ្តល់អត្ថប្រយោជន៍ផ្សេងៗដែលតម្រូវដោយច្បាប់ ដោយកិច្ចសន្យាការងារ ឬការអនុវត្តល្អប្រសើរជាសកល។ នៅពេលដែលសំណងមិនបានឆ្លើយតបនឹងតម្រូវការមូលដ្ឋានរបស់កម្មករ និងផ្តល់ប្រាក់ចំណូលមួយចំនួនតាមឆន្ទានុសិទ្ធិទេ អ្នកលក់ម្នាក់ៗត្រូវធ្វើការជាមួយ លូលូឡិមិន Lululemon ដើម្បីចាត់វិធានការណ៏សមស្រប ដើម្បីសម្រេចបានជាបណ្តើរៗនូវកម្រិតនៃប្រាក់សំណងដែលអាចបំពេញតម្រូវការមូលដ្ឋានរបស់ពួកគេ។ និយោជិតជាស្ត្រីត្រូវមានសិទ្ធិទទួលបានការការពារលើសិទ្ធិមាតុភាព - ការឈប់សម្រាក និងអត្ថប្រយោជន៍ក៏ដូចជាការការពារប្រឆាំងនឹងការរើសអើង – ស្របតាមតម្រូវការនៃច្បាប់ និងបទប្បញ្ញត្តិជាតិ។

### សេរីភាពនៃសមាគម និងការចរចាជាសមូហភាព

អ្នកលក់ត្រូវទទួលស្គាល់ និងគោរពសិទ្ធិរបស់និយោជិតក្នុងការចូលរួម និងការរៀបចំសមាគមតាមការជ្រើសរើសរបស់ពួកគេផ្ទាល់ និងការចរចាជាសមូហភាពដោយគ្មានការជ្រៀតជ្រែកពីអ្នកលក់។ ក្នុងករណីដែលសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងការចរចាជាសមូហភាពមានការដាក់កំហិតនៅក្រោមច្បាប់ នោះអ្នកលក់ត្រូវជួយសម្រួល និងមិនរារាំងការអភិវឌ្ឍមធ្យោបាយសមស្របសម្រាប់សមាគមឯករាជ្យ និងមានលក្ខណៈសេរី ព្រមទាំងការចរចាជាសមូហភាពឡើយ។

### ទំនាក់ទំនងការងារ

អ្នកលក់ត្រូវយល់ព្រមនិងប្រកាន់ខ្ជាប់នូវវិធានច្បាប់ និងលក្ខខណ្ឌការងារដែលគោរពដល់កម្មករ និងយ៉ាងហោចណាស់ការពារសិទ្ធិរបស់ពួកគេទៅតាមច្បាប់ និងបទប្បញ្ញត្តិជាតិ និងអន្តរជាតិស្តីពីការងារ និងសន្តិសុខសង្គម។

### មានភាពសេរីក្នុងការជ្រើសរើសការងារ

អ្នកលក់មិនត្រូវប្រើកម្លាំងពលកម្មដោយបង្ខិតបង្ខំក្នុងការជ្រើសរើសបុគ្គលិក ការជួល ឬការផ្តល់ការងារដែលរួមមានជាអាទិ៍ ការងារបន្ថែមម៉ោងដោយគ្មានការស្ម័គ្រចិត្ត ការជួញដូរកំលាំងពលកម្ម ប្រើប្រាស់ពលកម្មអ្នកជាប់ទោសក្នុងពន្ធនាគារ ការធ្វើការងារដោះដូរនឹងអត្ថប្រយោជន៍ ឬការធ្វើការដោះបំណុលឡើយ។

### ការមិនរើសអើង

អ្នកលក់មិនត្រូវរើសអើងក្នុងការជ្រើសរើសបុគ្គលិក និងការអនុវត្តការងារឡើយ។ និយោជិតទាំងអស់មានសិទ្ធិស្មើគ្នាចំពោះការងារដែលរួមមាន ការជួលប្រាក់ឈ្នួល អត្ថប្រយោជន៍ ការរីកចម្រើន ការបណ្តុះបណ្តាល ការបែងចែកការងារ ឬការចូលនិវត្តន៍ ហើយមិនត្រូវទទួលរងការរើសអើងចំពោះការដាក់វិន័យ ឬការបញ្ឈប់ការងារ ដោយផ្អែកលើពូជសាសន៍ ភេទ អត្តសញ្ញាណភេទ សាសនា សញ្ជាតិ ស្ថានភាពអាពាហ៍ពិពាហ៍ ជនជាតិដើម វង្សត្រកូលទំនោរផ្លូវភេទ ពិការភាពជំងឺ ភាពមានផ្ទៃពោះ អាយុ ភាសា ដើមកំណើតសង្គម ស្ថានភាពចំណាកស្រុក សមាជិកភាព ឬការអាណិតអាសូរនៅក្នុងសមាគមរបស់កម្មករនិយោជិតដែលរួមមាន សហជីព សម្ព័ន្ធភាពនយោបាយ ឬជំនឿ លក្ខណៈបុគ្គលផ្សេងទៀត ក្រុមសង្គម ឋានៈដែលទទួលបានការការពារ ឬឋានៈផ្សេងៗទៀតឡើយ។

### ម៉ោងធ្វើការ និងការធ្វើការថែមម៉ោង

អ្នកលក់មិនត្រូវទាមទារឱ្យកម្មករនិយោជិតធ្វើការលើសពី ៤៨ ម៉ោងក្នុងមួយសប្តាហ៍ធ្វើការធម្មតាឡើយ។ រាល់ការងារបន្ថែមម៉ោងត្រូវតែស្ម័គ្រចិត្តផ្តល់សំណងតាមអត្រាបុព្វលាភ ហើយមិនត្រូវស្នើសុំជាទៀងទាត់ទេ។ អ្នកលក់ត្រូវតែផ្តល់ជូននូវការឈប់សម្រាករយៈពេល ២៤ ម៉ោងជាប់គ្នារៀងរាល់ ៧ ថ្ងៃម្តងក៏ដូចជាការឈប់សម្រាកតាមច្បាប់ និងថ្ងៃឈប់សម្រាកបុណ្យទានផងដែរ។ អ្នកលក់ត្រូវតែធានាថាម៉ោងធ្វើការរបស់កម្មករនិយោជិតរួមទាំងការថែមម៉ោងមិនលើសពី ៦០ ម៉ោងក្នុងមួយសប្តាហ៍ ឬមិនលើសពីការកំណត់របស់ច្បាប់ក្នុងស្រុកនោះទេ ពោលគឺយកមួយណាដែលមានចំនួនតិចជាង លើកលែងតែក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ។ ពេលវេលាសម្រាកត្រូវតែគោរពតាមច្បាប់ និងបទប្បញ្ញត្តិជាតិ។

**សូមទាក់ទងមកយើងដោយផ្ទាល់ក្នុងករណីមានការមិនគោរពតាមក្រមសីលធម៌នេះ នៅកន្លែងធ្វើការជាភាសាណាមួយតាមជម្រើសរបស់អ្នកតាមរយៈ**
**sustainablepartner@lululemon.com**